# ចងក្រងទុកបទពិសោធន៍ជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំង

## ប្រវត្តិដើម

សន្ទុះនៃការបង្កើតបណ្ណសារដ្ឋាន មានប្រភពពីសហគមន៍ជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំង។ បណ្ឌិត ហ៊ាម ការដុង ដែលជាសមាជិកសហគមន៍វៀតណាមអាមេរិកាំងនៅ អូរេង់ខោនធី បានឲ្យយោបល់ទៅ អ្នកផ្នែការ UCI នៅពាក់កណ្តាលទសវត្សរ៍៨០។

ដោយហេតុនេះហើយ ទើបបណ្ណាល័យ UCI បាន បង្កើតបណ្ណសារដ្ឋាននេះ នៅឆ្នាំ១៩៨៧ ក្នុងគោលបំណងកត់ត្រាទុកនូវបទពិសោធន៍របស់ជនជាតិអាស៊ីភាគអាគ្នេយ៍ ដែលទើបតែមកដល់នៅអូរេង់ខោនធី។ ឯកសារដែលយើងមានមុនដំបូងបានមកពីសប្បុរសជនទូទាំងរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក និងពីបរទេស។ ឯកសារជំនាន់ដើមកត់ត្រាពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់សប្បុរសជន ដែលជាជនភៀសខ្លួន និងផ្តល់នូវសារតារស្តីពីវប្បធម៌ និង មាតុភូមិរបស់គេ។ ឯកសារខ្លះទៀតបានមកពីអ្នកធ្វើការជាមួយជនភៀសខ្លួន និងពីអតីតយុទ្ធជនអាមេរិកាំង។

ដោយសារតែបណ្ណសារដ្ឋានបានរីកចម្រើន យើងក៏បានប្រមូលទុកនូវឯកសារដែលទាក់ទងនឹងជនជាតិអាមេរិកាំងដែលមានដើមកំណើតពីអាស៊ីភាគអាគ្នេយ៍នៅទូទាំងសហរដ្ឋអាមេរិក រួមទាំងក្រុមជនជាតិតូចៗដូចជា ថាមតៃដាម (Tai Dam) ខ្មុ (Kmhmu) អ៊ីវមៀន (Iu Mien) និងឡាហ៊ូ (Lahu)។ យើងនៅតែ ផ្តោតអារម្មណ៍ទៅ ជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំងនៅអូរេង់ខោនធី និងរដ្ឋកាលីហ្វ័រញ៉ា។ គោលបំណងរបស់ បណ្ណសារដ្ឋានគឺថែរក្សានិងកត់ត្រាទុក នូវសង្គម វប្បធម៌ សាសនា នយោបាយ និងជីវិតសេដ្ឋកិច្ច របស់ជនជាតិអាមេរិកាំងដែលមានដើមកំណើតជាជនជាតិអាស៊ីភាគអាគ្នេយ៍ ដោយចាប់ផ្តើមពីការភៀសខ្លួនពី អាស៊ីភាគអាគ្នេយ៍នៅឆ្នាំ១៩៧៥ និងបន្តទៅអនាគតនៅពេលដែលសហគមន៍របស់គេចម្រើនលូតលាស់។

មូលនិធិជាតិសម្រាប់មនុស្សធម៌ និងបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ាបានឧបត្ថមជាថវិកាដល់ បណ្ណសារដ្ឋាន ដែលជាកិត្តិយស និងការទទួលស្គាល់ពីសារៈសំខាន់នៃបណ្ណសារដ្ឋាន។




## របៀបដែលលោកអ្នកអាចជួយបណ្ណសារដ្ឋាន

បណ្ណសារដ្ឋានកំពុងតែមមាញឹកក្នុងការស្វែងរកអំណោយជាវត្ថុ ដែលអាចបង្គ្រប់កង្វះខាត និងធ្វើឲ្យកាន់តែសំបូរដល់បណ្ណសារដ្ឋាន ជាពិសេសឯកសារដែលកត់ត្រាពីសកម្មភាពបុគ្គល អង្គការនានា ពាណិជ្ជកម្មនិងព្រឹត្តិការណ៍ក្នុងសហគមន៍ជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំង។ សូមមេត្តាទាក់ទងយើងខ្ញុំបើលោកអ្នកមានវត្ថុដែលលោកអ្នកចង់ធ្វើជាអំណោយ ឬអនុញ្ញាតឲ្យយើងខ្ញុំថតចម្លង។

For more information please contact:

Orange County & Southeast Asian Archive Center
(OC & SEAA)
Visit: Libraries Gateway Study Center, Room 104
Mail: UC Irvine Libraries
P.O. Box 19557
Irvine, CA 92623-9557
Email: spcoll@uci.edu
Phone: (949) 824-3947
Web: ocseaa.lib.uci.edu

សៀវភៅស្តើងនេះមានជាភាសាអង់គ្លេស ខ្មែរ ម៉ុង លាវ និងវៀតណាម។

ឧបត្ថម្ភការបោះពុម្ពដោយបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ា ក្រោមច្បាប់ សេវ៉ាបណ្ណាល័យ និងបច្ចេកវិជ្ជា (Library Services and Technology Act)។








បណ្ណសារដ្ឋានជនជាតិអាស៊ីភាគអាគ្នេយ៍
បណ្ណាល័យ
សាកលវិទ្យាល័យនៃរដ្ឋកាលីហ្វ័រញ៉ា អឺវ៉ាញ





## គោលបំណងរបស់យើង

បណ្ណសារដ្ឋាននៃជនជាតិអាស៊ីភាគអាគ្នេយ៍ របស់បណ្ណាល័យសាកលវិទ្យាល័យ នៃរដ្ឋកាលីហ្វ័រញ៉ា អឺវ៉ាញ មានគោលបំណង ចងក្រងទុកនូវឯកសារជនភៀសខ្លួន និងជនអន្តោប្រវេសន៍ ពីឥណ្ឌូចិន ដែលមានប្រទេសកម្ពុជា លាវ និងវៀតណាម ដែលបានមកតាំងទីលំនៅក្នុងសហរដ្ឋអាមេរិក តាំងពីពេលបញ្ចប់សង្រ្គាមនៅប្រទេសវៀតណាម ក្នុងឆ្នាំ១៩៧៥។ តាមជំរឿននៃសហរដ្ឋអាមេរិកឆ្នាំ២០០០ មានជនជាតិខ្មែរ លាវ និងវៀតណាម ចំនួន៦៣៨០០០ ដែលសព្វថ្ងៃរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។ ចំនួននេះគឺជិត៤០% នៃចំនួន ជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំងនៅសហរដ្ឋ អាមេរិក។ អូរេង់ ខោនធី មានជនជាតិវៀតណាមច្រើនជាងគេ នៅក្រៅប្រទេសវៀតណាម។ មានជនជាតិលាវច្រើនបង្គួរដែរ នៅសានឌីអេហ្គូ និងនៅសិនត្រាល់វ៉ាលៃ រួមទាំងនៅតំបន់សានហ្វ្រាំនស៊ីស្កូ។ ហើយនៅទីក្រុងឡុងប៊ិច មានជនជាតិខ្មែរ ច្រើនជាងគេ នៅក្រៅប្រទេសកម្ពុជា។ ដោយហេតុនេះ ហើយ សាកលវិទ្យាល័យ នៃរដ្ឋកាលីហ្វ័រញ៉ា អឺវ៉ាញ (UCI) ដែលឋិតនៅក្នុងតំបន់ បានចងក្រងទុក និងថែរក្សា នូវបទពិសោធន៍របស់ក្រុមពលរដ្ឋអាមេរិកាំងថ្មីនេះ។

## សារវត្ថុ

បណ្ណសារដ្ឋាននៃជនជាតិអាស៊ីភាគអាគ្នេយ៍ មានឯកសារច្រើនយ៉ាងជាភាសាអង់គ្លេស និងភាសាជនជាតិអាស៊ីភាគអាគ្នេយ៍ៗ យើងប្រមូលទុកនូវឯកសារដែលទាក់ទងនឹងបទពិសោធន៍នៃជំរៀសខ្លួន របស់ជនភៀសខ្លួនតាមទូក និងជនភៀសខ្លួនតាមផ្លូវគោក ការព្យាយាមតាំងទីលំនៅ នៅសហរដ្ឋអាមេរិក និងអនាគត ការចម្រើនលូតលាស់ និងដំណើរនៅមុខ របស់សហគមន៍ជនជាតិថ្មី ព្រមទាំងវប្បធម៌និងប្រវត្តិសាស្ត្រប្រទេសខ្មែរ លាវ និងវៀតណាម ដោយហេតុថាវប្បធម៌និងប្រវត្តិសាស្ត្រឆ្លុះបញ្ចាំងពីឫសដើមនៃវប្បធម៌របស់ជនភៀសខ្លួនៗ

សារវត្ថុនៅ បណ្ណសារដ្ឋានរួមមាន៖

- សិល្បៈ (គំនូរ)
- វត្ថុបុរាណ
- អត្ថបទពីទស្សនាវដ្តី និងទិនានុប្បវត្តិ
- សៀវភៅ
- សៀវភៅរាយឈ្មោះនិងទីលំនៅពាណិជ្ជកម្ម
- ការសរសេរទាក់ទងគ្នា
- បរមាធិប្បាយ និង និក្ខេបបទ
- ឯកសារសម្រាប់មួយវេលា (ខិត្តប័ណ្ណ សៀវភៅស្តើង កម្មវិធីៗលៗ)
- ភាពយន្ត វីដេអូ និង កាសែតសម្លេង
- ឯកសាររដ្ឋ
- ទស្សនាវដ្តី និងទិនានុប្បវត្តិ
- លិខិតពត៌មាន
- អត្ថបទដែលកាត់ពីសារពត៌មាន
- ឯកសាររបស់អង្គការ
- លិខិតខ្សែៗ
- រឿងនិទាន និងឯកសារផ្ទាល់ខ្លួន
- រូបថត
- ប័ណ្ណប្រកាស
- ឯកសារណែនាំជនភៀសខ្លួន
- របាយការណ៍
- ការស្ទង់មតិ












បណ្ណសារដ្ឋានមាន សារវត្ថុដ៏កម្ររកបានសម្រាប់អ្នកស្រាវជ្រាវ។ ឧទាហរណ៍ខ្លះៗ៖

ឯកសារ Mitchell I. Bonner ឆ្នាំ 1975-1990s.
ឯកសារជាអក្សរនិងរូបថតដែលភាគច្រើនកត់ត្រានូវជនជាតិអាស៊ីភាគអាគ្នេយ៍អាមេរិកាំងនៅតំបន់ឆកសានហ្វ្រានស៊ីស្កូ ជាពិសេសជនជាតិលាវអាមេរិកាំងៗ

ឯកសារ KimHà ឆ្នាំ 1983-1997.
ឯកសារមិនទាន់បោះពុម្ពរបស់ Kim Ha និទានពីការភៀសខ្លួនរបស់គ្រួសារនាង តាមផ្លូវគោកពីវៀតណាមទៅ ជំរំជនភៀសខ្លួននៅប្រទេសថៃៗ

ឯកសារ Brigitte Marshall ឆ្នាំ 1980s-1990s
ឯកសារបោះពុម្ព និងឯកសារជាសម្លេងនិងរូបភាពដែលកត់ត្រាពីជនភៀសខ្លួន (ជាពិសេសជនជាតិម៉ុង) នៅក្នុងជំរំនៅប្រទេសថៃ និងការមកតាំងទីលំនៅនៅរដ្ឋកាលីហ្វ័រនីញ៉ា ជាពិសេសនៅតំបន់សិនត្រាល់វ៉ាលៃៗ

Southeast Asian Resource Action Center (SEARAC) Records, 1975-1996. បញ្ជីរបស់ មជ្ឈមណ្ឌលសកម្មភាពធនធាននៃជនជាតិអាស៊ីភាគអាគ្នេយ៍ដ៏ធំនេះ ដែលមានទីតាំងនៅរដ្ឋធានីវ៉ាស៊ីនតោនៗ មជ្ឈមណ្ឌលនេះមានកំណើតក្នុងគោលបំណងជួយដល់ការមកតាំងទីលំនៅនៃជនភៀសខ្លួនទូទាំងប្រទេសៗ

## យើងស្វាគមន៍ភ្ញៀវទាំងអស់

អ្នកប្រើប្រាស់ បណ្ណសារដ្ឋាននៃជនជាតិអាស៊ីភាគអាគ្នេយ៍រួមមាន និស្សិតមហាវិទ្យាល័យនិងសាស្ត្រាចារ្យគ្រូបង្រៀន និងសិស្សានុសិស្ស សកម្មជនក្នុងសហគមន៍ អ្នកសារពត៌មាន និងក្រុមមេធាវីៗ ការប្រើប្រាស់បណ្ណ សារដ្ឋាន មិនត្រូវការប័ណ្ណសំគាល់ខ្លួន ឬការអនុញ្ញាតទេ ក៏ប៉ុន្តែ លោកអ្នកត្រូវមានប័ណ្ណបណ្ណាល័យ UC ទើបអាចខ្ចីឯកសារបានៗ លោកអ្នកអាចខ្ចីនូវឯកសារ(ដែលអាចឲ្យខ្ចីបាន) តាមរយៈការខ្ចីពីបណ្ណាល័យមួយទៀត (Interlibrary Loan)ៗ ឯកសារភាគច្រើនអាចថតចម្លងបានៗ

## ការទាក់ទងនឹងសហគមន៍

សហគមន៍ជនជាតិអាស៊ីភាគអាគ្នេយ៍បានផ្តល់ឲ្យជាច្រើនដល់ បណ្ណសារដ្ឋានរួមមាន ចំណេះដឹង ការទាក់ទង ជំនាញការ និងអំណោយសារវត្ថុៗ ជាការតបស្នង បណ្ណសារដ្ឋានផ្តល់ជូនវិញតាមដែលអាចធ្វើបានៗ

ក្រុមទីប្រឹក្សាដែលមានសមាជិកពីសហគមន៍ និងអ្នកសិក្សា ត្រូវបាន បង្កើតឡើងនៅឆ្នាំ ១៩៩៧ ដើម្បីធ្វើឲ្យកិច្ចប្រឹងប្រែងក្នុងការទាក់ទងនឹងសហគមន៍របស់បណ្ណសារដ្ឋានមានការរីកចំរើន រក្សានូវទំនាក់ទំនងជិតស្និទ្ធរវាងសហគមន៍ និងសាកលវិទ្យាល័យ ព្រមទាំងជាជំនួយក្នុងការប្រមូលផ្តុំឯកសារៗ

មានការជូនទស្សនា បណ្ណសារដ្ឋាន ជាញឹកញាប់ដល់សិស្សានុសិស្ស សកម្មជនក្នុងសហគមន៍ ភ្ញៀវសាកលវិទ្យាល័យ និងក្រុមដទៃទៀតៗ

យើងមានបោះពុម្ពលិខិតពត៌មានរបស់បណ្ណសារដ្ឋានដែលចេញផ្សាយបីខែម្តង ហើយដែលអាចអានបានតាមរយៈ គេហទំព័រៗ លិខិតពត៌មាននេះ ផ្ញើទៅដល់មនុស្ស និងអង្គការនានានៅទូទាំងប្រទេស ចំនួន៥០០ច្បាប់ៗ

គេហទំព័ររបស់បណ្ណសារដ្ឋានគឺ sea.lib.uci.edu ដែលមានទាក់ទង ទៅនឹងគេហទំព័រស្រដៀងគ្នាដទៃជា ច្រើនទៀត អត្ថបទផ្សេងៗនៅក្នុងលិខិតពត៌មាន ការតាំង ពិព័ណ៌ដែលមានចំណងជើងថា «ចងក្រងទុកបទពិសោធន៍ជនភៀសខ្លួនជនជាតិអាស៊ីភាគអាគ្នេយ៍» ឧទាហរណ៍ស្តីពី Hmong *paj ntaub* ព្រមទាំង អត្ថបទគន្ថនិទ្ទេស (topical bibliographies)ៗ

## អត្ថបទបោះពុម្ពដោយបណ្ណសារដ្ឋានជនជាតិអាស៊ីភាគអាគ្នេយ៍

Archibold, Randal C. (1997, January 26). Preserving pieces of refugee experience. *Los Angeles Times*, pp. A1, A20.

Bà Anne Frank - Đại Học UCI giới thiệu thư viện - Văn Khố Đông Nam Á. (1999, April-May). *Văn Hóa* 44, A47-48.

Fujita Rony, Dorothy, & Frank, Anne. (2003). Archiving histories: The Southeast Asian Archive at University of California, Irvine. *Amerasia Journal* 29(1).






